# វ៉ាក់សាំងជំងឺ COVID-19 និងសុខភាពបន្តពូជ
# សំណួរចោទសួរជាញឹកញាប់

Vaccinate WA
CovidVaccineWA.org

វាជារឿងធម្មតាដែលមានក្តីកង្វល់អំពីរបៀបដែលវ៉ាក់សាំងជំងឺ COVID-19 អាចនឹងប៉ះពាល់ដល់សុខភាពបន្តពូជ។ Centers for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ ) ណែនាំឱ្យចាក់វ៉ាក់សាំងសម្រាប់អ្នកគ្រប់គ្នាដែលមានអាយុ 6 ខែឡើងទៅ រួមទាំងបុគ្គលដែលកំពុងព្យាយាមមានផ្ទៃពោះនៅពេលនេះ ឬអាចនឹងមានផ្ទៃពោះនាពេលអនាគត។ បច្ចុប្បន្ននេះ គ្មានភស្តុតាងណាមួយបង្ហាញថាវ៉ាក់សាំងណាមួយ រួមទាំងវ៉ាក់សាំងជំងឺ COVID-19 បង្កឱ្យមានបញ្ហាពាក់ព័ន្ធនឹងលទ្ធភាពមានកូននៅពេលនេះ ឬអនាគតនោះទេ។

អ្នកអានមួយចំនួនអាចនឹងប៉ះពាល់អារម្មណ៍ជាមួយនឹងប្រធានបទក្នុងឯកសារនេះ ដោយសារតែធ្លាប់ពិបាកនឹងមានកូន ធ្លាប់មានប្រវត្តិប៉ះទង្គិចផ្លូវចិត្តដោយសារការរើសអើងជាតិសាសន៍លើពណ៌សម្បុរ ការត្អូញត្អែរទូទៅអំពីសុខភាពដែលគេមិនអើពើរបស់ស្ត្រី/ស្ត្រីប្តូរភេទទៅជាបុរស និងស្ត្រី/ភេទដែលខុសពីការរំពឹងទុកនៅក្នុងដែនវេជ្ជសាស្ត្រ។

**មើលខាងក្រោម ដើម្បីស្វែងយល់អំពីចម្លើយចំពោះសំណួរទូទៅអំពីវ៉ាក់សាំងជំងឺ COVID–19 និងសុខភាពបន្តពូជ។**

## *សំណួរ៖ តើលទ្ធភាពមានកូនរបស់ខ្ញុំនឹងប៉ះពាល់ដោយសារវ៉ាក់សាំងជំងឺ COVID–19 ដែរទេ?*

***ចម្លើយ៖***

គ្មានភស្តុតាងណាមួយបង្ហាញថាវ៉ាក់សាំងណាមួយ រួមទាំងវ៉ាក់សាំងជំងឺ COVID-19 ប៉ះពាល់ដល់លទ្ធភាពមានកូននោះទេ មិនថាមានភេទអ្វីក៏ដោយ។ វ៉ាក់សាំងនានាដំណើរការជាមួយប្រព័ន្ធភាពស៊ាំនៃរាងកាយរបស់អ្នក ដើម្បីតតាំងនឹងវីរុសកូរ៉ូណា ហើយមិនរំខានដល់សរីរាង្គបន្តពូជរបស់អ្នកទេ។ ក្នុងការពិសោធសាកល្បងវេជ្ជសាស្ត្រលើវ៉ាក់សាំងជំងឺ COVID-19 និងក្នុងការស្រាវជ្រាវយ៉ាងទូលំទូលាយលើគូស្នេហ៍ដែលព្យាយាមមានផ្ទៃពោះ គេឃើញថាអត្រាមានផ្ទៃពោះគឺដូចគ្នារវាងគូស្នេហ៍ដែលបានចាក់វ៉ាក់សាំងជំងឺ COVID-19 និងគូស្នេហ៍ដែលមិនបានចាក់វ៉ាក់សាំង។ វ៉ាក់សាំងជំងឺ COVID-19 គឺមានសុវត្ថិភាព និងប្រសិទ្ធភាព។ Centers for Disease Control and Prevention (CDC), American College of Obstetricians and Gynecologists (ACOG, មហាវិទ្យាល័យសម្ភពនិងរោគស្ត្រីអាមេរិកាំង ) និង Society for Maternal-Fetal Medicine (SMFM, អង្គការសង្គមវេជ្ជសាស្ត្រមាតានិងទារក ) ណែនាំឱ្យចាក់វ៉ាក់សាំងជំងឺ COVID-19 សម្រាប់មនុស្សដែលមានផ្ទៃពោះ បំបៅដោះកូន ឬគ្រោងនឹងមានផ្ទៃពោះ។

ចូលមើលតំណភ្ជាប់នេះដើម្បីស្តាប់ប្រសាសន៍របស់វេជ្ជបណ្ឌិត LaSalle អំពីមូលហេតុដែលណែនាំឱ្យចាក់វ៉ាក់សាំងជំងឺ COVID៖ លទ្ធភាពមានកូន និងវ៉ាក់សាំងជំងឺ COVID-19 - YouTube

## *សំណួរ៖ តើវ៉ាក់សាំងនេះនឹងផ្លាស់ប្តូរវដ្តរដូវរបស់ខ្ញុំដែរឬទេ?*

***ចម្លើយ៖***

បុគ្គលដែលបានចាក់វ៉ាក់សាំងជំងឺ COVID-19 មួយចំនួនបានរាយការណ៍អំពីការប្រែប្រួលវដ្តរដូវបន្ទាប់ពីចាក់វ៉ាក់សាំង ដូចជាមានរយៈពេលយូរជាងមុន ខួបរដូវពីមួយទៅមួយខ្លីជាងមុន ឬឈាមច្រើនជាងធម្មតា។ ក្នុងការស្រាវជ្រាវនៅឆ្នាំ 2022 គេរកឃើញថាបុគ្គលមានរដូវដែលបានចាក់វ៉ាក់សាំងជំងឺ COVID-19 មានវដ្តរដូវតិចជាងមុនមួយថ្ងៃកាន់តែច្រើនឡើង ជុំវិញរយៈពេលចាក់ដូសរបស់ខ្លួន។ ការប្រែប្រួលមួយថ្ងៃគឺស្ថិតក្នុងចន្លោះធម្មតានៃការប្រែប្រួលវដ្តរដូវ។ ទោះជាអាចមានការប្រែប្រួលបណ្តោះអាសន្នទាំងនេះក្នុងវដ្តរដូវក្តី គ្មានភស្តុតាងណាមួយបញ្ជាក់ថាវ៉ាក់សាំងជំងឺ COVID–19 បង្កឱ្យមានបញ្ហាពាក់ព័ន្ធនឹងលទ្ធភាពមានកូនទេ។ ការប្រែប្រួលវដ្តរដូវរបស់អ្នកអាចធ្វើឱ្យពេលវេលាបញ្ចេញអូវ៉ុលប្រែប្រួល។ មនុស្សដែលប្រើផែនការគ្រួសារតាមធម្មជាតិ និងវិធីផ្សេងទៀតដែលពឹងផ្អែកលើការតាមដានវដ្តរដូវ ប្រហែលជាពិបាកនឹងដឹងពីពេលវេលាបញ្ចេញអូវ៉ុល និងបញ្ចៀស/គ្រោងនឹងមានផ្ទៃពោះ។ សូមពិគ្រោះជាមួយអ្នកផ្តល់សេវារបស់អ្នក ដើម្បីពិភាក្សាអំពីវដ្តរដូវ និងស្វែងយល់បន្ថែមអំពីផែនការគ្រួសារ។

## *សំណួរ៖ តើវ៉ាក់សាំងជំងឺ COVID–19 អាចប៉ះពាល់ដល់ការពន្យារកំណើតទេ?*

***ចម្លើយ៖***

យោងតាមអង្គការ Planned Parenthood គ្មានភស្តុតាងបញ្ជាក់ថា វ៉ាក់សាំងជំងឺ COVID-19 ធ្វើឱ្យការពន្យារកំណើតមានប្រសិទ្ធភាពទាប ឬខ្ពស់ជាងមុនទេ។ នៅពេលនេះ គ្មានរបាយការណ៍ពីបុគ្គលដែលបានចាក់វ៉ាក់សាំងថា ការពន្យារកំណើតរបស់ពួកគេលែងមានប្រសិទ្ធភាពបន្ទាប់ពីចាក់វ៉ាក់សាំងទេ។ ទោះបីជាមានរបាយការណ៍អំពីការប្រែប្រួលវដ្តរដូវ ក៏វាមិនប៉ះពាល់ដល់ប្រសិទ្ធភាពពន្យារកំណើតរបស់មនុស្សដែរ។ ប្រការនេះអាចបង្កការពិបាកក្នុងការតាមដានវដ្តរដូវ និងរយៈពេលបញ្ចេញអូវ៉ុល។ មនុស្សដែលប្រើការពន្យារកំណើតតាមធម្មជាតិ ដូចជាវិធីយល់ដឹងអំពីលទ្ធភាពមានកូនជាដើម ប្រហែលជាពិបាកនឹងដឹងពីពេលវេលាបញ្ចេញអូវ៉ុល។ មានឧបករណ៍ដែលអាចជួយបុគ្គលនានាក្នុងការតាមដានការបញ្ចេញអូវ៉ុល។ យើងសូមណែនាំឱ្យពិគ្រោះជាមួយអ្នកផ្តល់សេវារបស់អ្នកអំពីជម្រើស និងដើម្បីស្វែងយល់បន្ថែម។

## សំណួរ៖ តើវ៉ាក់សាំងអាចប៉ះពាល់ដល់ស្ពែម និង/ឬបង្កឱ្យអសមត្ថភាពផ្លូវភេទដែរទេ?

**ចម្លើយ៖** គ្មានភស្តុតាងណាមួយបង្ហាញថាវ៉ាក់សាំងណាមួយ រួមទាំងវ៉ាក់សាំងជំងឺ COVID-19 ធ្វើឱ្យមនុស្សដែលមានសរីរាង្គបន្តពូជបុរសមានបញ្ហាពាក់ព័ន្ធនឹងលទ្ធភាពមានកូន ឬអសមត្ថភាពផ្លូវភេទនៅពេលនេះទេ។ ការស្រាវជ្រាវថ្មីតូចមួយទៅលើមនុស្សប្រុសដែលមានសុខភាពល្អចំនួន 45នាក់ដែលបានចាក់វ៉ាក់សាំងជំងឺ COVID-19 ស៊េរី mRNA បានពិនិត្យមើលលក្ខណៈរបស់ស្ពែម ដូចជាបរិមាណ និងចលនាជាដើម នៅមុននិងក្រោយពេលចាក់វ៉ាក់សាំង។ អ្នកស្រាវជ្រាវបានរកឃើញថា គ្មានការប្រែប្រួលគួរឲ្យកត់សម្គាល់ចំពោះលក្ខណៈរបស់ស្ពែមទាំងនេះ ក្រោយពេលចាក់វ៉ាក់សាំងទេ។ ក្រៅពីនេះ ការស្រាវជ្រាវមួយបានរកឃើញថា ការឆ្លងជំងឺ COVID-19 អាចពាក់ព័ន្ធនឹងលទ្ធភាពមានកូនចុះខ្សោយសម្រាប់បុរសរហូតដល់ 60 ថ្ងៃបន្ទាប់ពីឆ្លងជំងឺ។ គ្រុនក្តៅដោយសារជំងឺទាំងឡាយ និងរោគសញ្ញាទូទៅរបស់ជំងឺ COVID-19 ក៏អាចបណ្តាលឱ្យការផលិតស្ពែមថយចុះរយៈពេលខ្លីដែរ។ បើទោះបីជាគ្រុនក្តៅអាចជាផលរំខាននៃការចាក់វ៉ាក់សាំងជំងឺ COVID-19 ក៏មិនមានភស្តុតាងបច្ចុប្បន្នដែលបង្ហាញថាគ្រុនក្តៅក្រោយការចាក់វ៉ាក់សាំងជំងឺ COVID ប៉ះពាល់ដល់ការផលិតស្ពែមនោះទេ។ ពិគ្រោះជាមួយអ្នកផ្តល់សេវារបស់អ្នក ប្រសិនបើអ្នកមានក្តីកង្វល់បន្ថែម។

## សំណួរ៖ តើវ៉ាក់សាំងប៉ះពាល់ដល់ការធ្វើ IVF (ការចាក់ស្ពែមនិងអូវ៉ុលបញ្ចូលគ្នាក្នុងកែវ) ដែរទេ?

**ចម្លើយ៖** គ្មានភស្តុតាងដែលបង្ហាញថា វ៉ាក់សាំងជំងឺ COVID-19 ប៉ះពាល់ដល់លទ្ធផលធ្វើ IVF របស់មនុស្សទេ។ ការស្រាវជ្រាវបានរកឃើញថា គ្មានផលប៉ះពាល់ពីវ៉ាក់សាំងជំងឺ COVID-19 ស៊េរី mRNA ទៅលើអត្រាជោគជ័យនៃការធ្វើ IVF ទេ។ ការស្រាវជ្រាវមួយបានរកឃើញថាមិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ក្នុងប្រតិកម្មតបនឹងការរំញោចអូវែ គុណភាពស៊ុត ការវិវឌ្ឍអំប្រ៊ីយ៉ុង ឬលទ្ធផលមានផ្ទៃពោះរវាងបុគ្គលដែលបានចាក់វ៉ាក់សាំង ធៀបនឹងអ្នកជំងឺដែលមិនបានចាក់វ៉ាក់សាំង។ គេមិនបានរកឃើញថា វ៉ាក់សាំងជំងឺ COVID-19 ប៉ះពាល់ដល់លទ្ធភាពមានកូន ឬធ្វើឱ្យកាន់តែពិបាកសម្រាប់អ្នកដែលកំពុងតែពិបាកនឹងមានកូនស្រាប់ទេ។ វ៉ាក់សាំងជាច្រើនត្រូវបានចាក់ជាប្រចាំយ៉ាងមានសុវត្ថិភាព ទាំងក្នុងអំឡុង និងមុនពេលមានផ្ទៃពោះ ដូចជាវ៉ាក់សាំងផ្តាសាយធំ តេតាណូស និងខាន់ស្លាក់។ វ៉ាក់សាំង COVID-19 ត្រូវបានណែនាំឱ្យចាក់សម្រាប់មនុស្សដែលមានអាយុ 6 ខែឡើងទៅ រួមទាំងមនុស្សដែលព្យាយាមមានកូន។

## សំណួរ៖ តើវ៉ាក់សាំងជំងឺ COVID–19 អាចបណ្តាលឱ្យរលូតកូនដែរទេ?

**ចម្លើយ៖** ទេ វ៉ាក់សាំងជំងឺ COVID-19 មានសុវត្ថិភាពទាំងនៅមុន អំឡុង និងក្រោយពេលមានផ្ទៃពោះ។ មិនមានភស្តុតាងបង្ហាញថាការចាក់វ៉ាក់សាំងជំងឺ COVID-19 បង្កើនហានិភ័យនៃការរលូតកូនទេ។ គេមិនបានរកឃើញថាមានអត្រារលូតកូនកាន់តែខ្ពស់សម្រាប់បុគ្គលដែលបានចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺ COVID-19 ទេ។

អត្រារលូតកូនមានខ្ពស់ជាងការគិតរបស់មនុស្ស។ ប្រហែល 10 ទៅ 20 ភាគរយនៃការមានផ្ទៃពោះបញ្ចប់ដោយការរលូតកូន។ បុគ្គលមួយចំនួនដែលបានចាក់វ៉ាក់សាំងប្រហែលជាជួបបញ្ហារលូតកូន ប៉ុន្តែវាមិនពាក់ព័ន្ធនឹងវ៉ាក់សាំងទេ។ ការរលូតកូនអាចកើតឡើង ទោះបានចាក់ឬមិនបានចាក់វ៉ាក់សាំងក៏ដោយ។ តាមពិត មនុស្សដែលប្រែជាឈឺធ្ងន់ដោយសារជំងឺ COVID-19 នៅពេលមានផ្ទៃពោះថ្មីៗប្រឈមនឹងហានិភ័យនៃការរលូតកូនខ្ពស់ជាង។ ការចាក់វ៉ាក់សាំងគឺជាការការពារដ៏ល្អបំផុតសម្រាប់អ្នក និងកូនរបស់អ្នកប្រឆាំងនឹងជំងឺ COVID-19។

## ធនធានឯកសារ

Centers for Disease Control and Prevention, “COVID-19 Vaccines for People Who Would Like to Have a Baby”. 2022. មានលើអ៊ីនធឺណិតនៅ៖ COVID-19 Vaccines for People Who Would Like to Have a Baby | CDC

American College of Obstetricians and Gynecologists, ‘COVID-19 Vaccination Considerations for Obstetric-Gynecologic Care”. 2022. មានលើអ៊ីនធឺណិតនៅ៖ COVID-19 Vaccination Considerations for Obstetric–Gynecologic Care | ACOG

World Health Organization, “Questions and Answers: COVID-19 vaccines and pregnancy.” 2022. មានលើអ៊ីនធឺណិតនៅ៖ Questions and Answers: COVID-19 vaccines and pregnancy (who.int)

Mount Sinai, “Large Study Provides Reassurance that COVID-19 Vaccination Does Not Affect Fertility or Early Pregnancy.” 2022. មានលើអ៊ីនធឺណិតនៅ៖ Large Study Provides Reassurance that COVID-19 Vaccination Does Not Affect Fertility or Early Pregnancy | Mount Sinai - New York

*សូមពិគ្រោះជាមួយអ្នកជំនាញថែទាំសុខភាពដែលអ្នកជឿទុកចិត្តជានិច្ចអំពីការសម្រេចចិត្តផ្នែកវេជ្ជសាស្ត្រផ្ទាល់ខ្លួន។*

Washington State Department of Health

DOH 825-053 July 2022 Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 800-525-0127។ អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov